NEWS RELEASE

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

# សិក្ខាសាលាថ្នាក់តំបន់ ត្រូវបានប្រារព្វធ្វើ លើប្រធានបទ "អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ដែលធ្វើការក្នុងវិស័យដីធ្លី នៅអាស៊ីអាគ្នេយ៍"

រាជធានីភ្នំពេញ (២ ធ្នូ ២០១៤) - ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) បានរៀបចំសិក្ខាសាលាថ្នាក់តំបន់មួយ ដែលមានរយៈពេលពីរថ្ងៃ លើប្រធានបទ "អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ដែលធ្វើការក្នុងវិស័យដីធ្លីនៅអាស៊ីអាគ្នេយ៍" នៅថ្ងៃទី១-២ ខែធ្នូ ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពនេះ មានការអញ្ជើញចូលរួមពីអ្នកការពារសិទ្ធិមនុស្សជាស្ត្រីនៅថ្នាក់មូលដ្ឋាន ដែលមកពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ភូមា ថៃឡង់ដ៍ ហ្វីលីពីន និងកម្ពុជា ដែលបានផ្តល់ឱកាស មួយសម្រាប់ពួកគេ ពិភាក្សាគ្នាអំពីបញ្ហាប្រឈមដែលអ្នកការពារសិទ្ធិមនុស្សជាស្ត្រីជួបប្រទះ នៅពេលធ្វើការលើបញ្ហាពាក់ព័ន្ធ នឹងដីធ្លី និងធនធានធម្មជាតិ ដើម្បីចែករំលែកបទពិសោធន៍ និងដាក់ចេញជាយុទ្ធសាស្ត្រ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ និងបង្កើតឲ្យមានបរិយាកាស មួយងាយស្រួលនិងមានសុវត្ថិភាព សម្រាប់អ្នកការពារ សិទ្ធិមនុស្សជាស្ត្រី។ សិក្ខាសាលាថ្នាក់តំបន់នេះ នឹងរួមចំណែកដល់ការសិក្សាស្រាវជ្រាវ ដែលការិយាល័យ OHCHR បាននិងកំពុងធ្វើ អំពីថាតើអ្នកការពារសិទ្ធិមនុស្សជាស្ត្រីជួបប្រទះបញ្ហាអ្វីខ្លះ ហើយត្រូវដោះស្រាយបញ្ហា ទាំងនោះតាមរបៀបណា នៅក្នុងការងាររបស់ខ្លួនពាក់ព័ន្ធនឹងសិទ្ធិដីធ្លី។

ថ្លែងសុន្ទរកថាបើក លោកស្រី វ៉ាន់-ហ៊ីលី តំណាងការិយាល័យ OHCHR ប្រចាំកម្ពុជា បានលើកឡើងថា ទន្ទឹមនឹងអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ប្រឈមនឹងហានិភ័យ និងការរំលោភបំពាន ដូចគ្នានឹងសហការីរបស់គាត់ជាបុរសនោះ យើងកត់សំគាល់ឃើញថា ពួកគេមានភាពងាយរងគ្រោះបន្ថែមទៀត ដោយសារតែបញ្ហាយ៉េនឌ័ររបស់ពួកគេ ដូចជា ការការយាយីរំខាន និងរំលោភបំពានផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ការផ្តន្ទាទោសពីការប្រព្រឹត្តល្មើសនឹង "សីលធម៌" ការគំរាមកំហែងប្រឆាំងនឹងកូនៗរបស់ពួកគេ និងការវាយប្រហារ ផ្អែកលើហេតុផល យ៉េនឌ័រទៅលើកេរ្តិ៍ឈ្មោះរបស់ពួកគេ។ ហានិភ័យជាក់លាក់ខាងយ៉េនឌ័រ និងការគំរាមកំហែង ដែលតម្រូវឲ្យ មានការការពារ និងការគាំទ្រខាងវេទយិតយ៉េនឌ័រ"។

លោកស្រីបានកត់សំគាល់ផងដែរថា "វាបង្ហាញពីសញ្ញាណមិនល្អ អំពីសកម្មភាពផ្តាច់ការ ដែលក្នុងនោះសកម្មជនម្នាក់ក្នុងចំណោមសកម្មជនសិទ្ធិដីធ្លីឯទៀត ដែលគ្រោងនឹងចូលរួមជាមួយយើងនៅថ្ងៃនេះ គាត់មកពី

តំបន់ បឹងកក់ ត្រូវបានគេរាំងមិនឲ្យចូលរួម ដោយផ្អែកលើមូលហេតុថា គាត់ត្រូវបានតុលាការ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលមួយឆ្នាំ ដោយសារតែគាត់បានចូលរួមក្នុងការតវ៉ាអហិង្សាមួយ កាលពីពីរសប្តាហ៍មុននេះ។″

សិក្ខាសាលានេះ បង្កើតឱកាសសម្រាប់សិក្ខាកាមទាំងអស់ ផ្តល់ជាអនុសាសន៍សម្រាប់ ការបង្កើតឲ្យមាន បរិយាកាស ងាយស្រួល និងគត់មត់ថែមទៀត សម្រាប់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ក្នុងការបំពេញភារកិច្ច របស់ខ្លួន និងដើម្បីឲ្យគាត់បញ្ជូនអនុសាសន៍ទាំងនេះដោយផ្ទាល់ទៅរដ្ឋាភិបាល ស្ថាប័ន និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ និងអង្គការដទៃផ្សេងទៀត។

**ចប់**

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖*

***នៅរាជធានីភ្នំពេញ៖*** *កញ្ញា ប៊្រូស្រា រ៉ាម៉ាន់ (+៨៥៥ ០១២ ៧៩០ ១៧៨ ឬ តាមរយៈអ៊ីម៉ែល៖ brahman@ohchr.org*

សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈបណ្តាញព័ត៌មានសង្គម៖

**ហ្វេសប៊ុក៖** https://www.facebook.com/OHCHRCambodia
**ធ្វីតធើ៖**https://twitter.com/OHCHR_Cambodia